## ៨. សន្និដ្ឋាន

យោងលើលទ្ធផលនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលស្នើសុំដោយក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ** រួចមក ក្រុមការងារបានធ្វើការ សន្និដ្ឋានដូចខាងក្រោម :

**២៣៥.** ជាទូទៅវាយនភាពដីនៅតំបន់សម្បទាននេះមានមានសិលាមេ៤ប្រភេទគឺ : (១) -Lake bed depos its មានចំនួន ១០ហិកតា ស្មើនឹង ០.១២ភាគរយ (២) - Pediments មាន ៣២៣ហិកតា ស្មើនឹង ៣.៩៩ ភាគរយ (៣) - Peneplain laterite deposits ៧.៧៤៨ ហិកតា ស្មើនឹង ៩៥.៦៥ ភាគរយ និង (៤)- Phtanite មាន ១៩ ហិកតា ស្មើនឹង ០.២៣ ភាគរយ នៃផ្ទៃដីសរុប។

**២៣៦.** *នៅតំបន់ដីសម្បទាននេះប្រភពទឹកស្រទាប់លើមានមធ្យម។ ដោយសារថា នៅផ្នែកខាងត្បូង នៃតំបន់ដីសម្បទាន និងផ្នែកខាងត្បូងឈាងខាងកើតមាន**ស្ទឹងជីនិត** ហូរកាត់ក្បែរ ហើយដោយឡែក ផ្នែកខាងជើង និងខាងលិចនៃតំបន់សម្បទាន ក៏មានប្រភពទឹកស្រទាប់លើបានមកពីអូរ ព្រែក ធម្មជាតិមួយចំនួនដូចជា : អូរបឹងសំរោង អូរកំបោរ អូរកំបោររលួស និងជាមួយអូរត្រពាំងឈូក។ ក្រៅពីអូរ ទាំងបួននេះចេញគេសង្កេតឃើញមានត្រពាំងចំនួន០១ គឺត្រពាំងឈូក និងអូរតូចៗចំនួនពីរទៀតដែលមិនមាន ឈ្មោះនៅក្នុងផែនទី តែអូរតូចៗទាំងនេះមួយចំនួនត្រូវបានរីងអស់នៅចុងរដូវប្រាំង។ ពាក់ព័ន្ធទៅនឹងប្រភពទឹក នៅក្នុងតំបន់ទីតាំងគំរោង ទឹកស្រទាប់លើមានប្រភពហូរមកពីប៉ែកខាងលើ គឺភាគខាងជើងនៃទីតាំងគំរោង ឆ្ពោះទៅប៉ែកខាងត្បូងនៃទីតាំង និងមួយផ្នែកទៀតហូរពីទិសខាងលិចទៅទិសខាងកើត រួចបន្តហូរចូលទៅក្នុងប្រភពទឹកស្ទឹងជីនិត មុននឹងបន្តហូរចូលទៅក្នុងបឹងទន្លេសាប។*

**២៣៧.** តាមរយៈរូបភាព Photo Index Maps នៅលើចំណុចទាំង១៦ Photo Index A, B, C, D, E, F, G, H, I, J, K, L, M, N, O, P) បង្ហាញអោយឃើញថា គំរបព្រៃនិងធនធាន ព្រៃឈើមានលក្ខណៈជាព្រៃស្រោង ដែលទទួលរងការរំខានធ្ងន់ធ្ងរ ឬអាចយល់បានថាជាព្រៃផ្សេងៗ ដែលរចេរឹល ចំណែកដីដែលគ្មានព្រៃ គឺជាដីដែលក្រុមហ៊ុនធ្វើការឈូសឆាយដាំដើមកៅស៊ូគ្រប់ចំនួនលើផ្ទៃដីដែលអាច ធ្វើអាជីវកម្មបានកាលពី ២-៣ឆ្នាំមុន។ ព្រៃដែលមាននៅសេសសល់ក្នុងតំបន់នេះគឺជាព្រៃ (១) ព្រៃតំបន់ទ្រនាប (២) ព្រៃតំបន់ការពារសំរាប់ធ្វើការស្តារព្រៃឡើងវិញ។

**២៣៨.** ការសិក្សាទៅលើរូបភាពនេត្រាទស្សន៍-១ អំពីស្ថានភាពនៃការប្រើប្រាស់ដីក្នុងតំបន់គំរោងអភិវឌ្ឍន៍ បង្ហាញថា ព្រៃឈើទាំងនេះមានលក្ខណៈជាព្រៃចំរុះ ស្ថានភាពគំរបព្រៃមានលក្ខណៈមធ្យម និងមានការរំខានពីការកាប់រានធ្វើចំការរបស់ប្រជាជននៅរួចទៅហើយ ប៉ុន្តែត្រូវអន្តរក្រសួងរក្សាទុកសំរាប់ស្តារព្រៃឡើងវិញ។

Draft

ចំពោះរូបភាពនៃគ្រាទស្សន៍-២,៣ និង៤ សង្កេតឃើញ មានដីវាលដែលបានឈូសឆាយដោយក្រុមហ៊ុន ដើម្បីដាំដំណាំកៅស៊ូនៅក្នុងតំបន់នោះ។ តាមការជួបសន្ទនាជាមួយលោកអភិបាលស្រុក និងអាជ្ញាធរមូលដ្ឋានបានអោយដឹងថា នៅក្នុងតំបន់ដូចបានរៀបរាប់ខាងដើមនេះពិតជាមានដីចំការស្វាយចន្ទី និងដីស្រែចំការចាស់របស់ពួកគាត់មែនតែត្រូវបានក្រុមហ៊ុនដោះស្រាយឱ្យរួចហើយ តែនៅមានសេសសល់តិចតួចប៉ុណ្ណោះតាមមាត់អូរទឹកថ្លា ដែលជាភូមិទើបនឹងបង្កើតថ្មីតែក៏ក្រុមហ៊ុនមិនប៉ះពាល់ដែរគឺទុកឱ្យគាត់ប្រកបរចិញ្ចឹមជីវិត។

**២៣៩.** នៅក្នុងប្រភេទព្រៃស្រោងរបស់តំបន់សម្បទាន មានរុក្ខជាតិចំនួន ៦០ប្រភេទ ជុល្លិព្រឹក្ស៤៤ប្រភេទ និងតិណជាតិចំនួន ៥៥ប្រភេទ ខាងក្រោម។ ភាពសម្បូរណ៍បែប និងសមាសភាពនៃរុក្ខជាតិ ទាំងនោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងការពន្យល់បកស្រាយពីរចនាសម្ព័ន្ធទីជំរក លោក Scweithelm and Chhay 2007 បាននិយាយថា នៅក្នុង ព្រៃល្បោះគ្របដណ្តប់ដោយប្រភេទរុក្ខជាតិ ដូចជា ខ្លុង ត្បែង ផ្ចឹក រាំងភ្នំ នាងផ្អែក ក្នុងពេលដែលពពួកស្បូវ និងស្មៅព្រិច ជាពពួករុក្ខជាតិថ្នាក់ក្រោម។ ចំណែកឯនៅក្នុងព្រៃពាក់កណ្តាលស្រោងវិញ សម្បូរណ៍ទៅដោយ *Lagerstroemia cochinchinesis*, *Xylia xylocarpa*, *Cratoxylum conchinchinense*, and *Shorea siamensis*, *Irivingia malayana* and that understory *Arundinaria pusilla* and *Bambusa bambos*.

**២៤០.** ការសិក្សាបានបង្ហាញថា ភាពសំបូរបែបនៃសត្វស្លាបមួយចំនួនដែលបានកត់ត្រានៅក្នុងតំបន់សិក្សាស្រាវជ្រាវ គឺមានចំនួនស្មើនឹង ៦៤ភាគរយ នៃលទ្ធផលដែលទទួលបានពីការសំភាសន៍ជាមួយប្រជាជនមូលដ្ឋានរស់ក្បែរតំបន់ស្រាវជ្រាវនឹងត្រូវជា ០៥ភាគរយ នៃចំនួនសត្វស្លាបសរុបក្នុងប្រទេសកម្ពុជា។ ចំណែកឯថនិកសត្វមានចំនួន ០៥ប្រភេទដែលជួបប្រទះនៅក្នុងតំបន់ដីគំរោងវិនិយោគ ហើយថនិកសត្វដែលកត់ត្រាបានមានចំនួនប្រមាណ ៣៣,៣៤ភាគរយ នៃចំនួនសត្វដែលបានពីការសំភាសន៍ប្រជាជនមូលដ្ឋាន ហើយត្រូវជា ២,៩៥ភាគរយ នៃចំនួនថនិកសត្វសរុបនៅក្នុងប្រទេសកម្ពុជា។ ចំពោះមច្ឆាជាតិវិញ នៅក្នុងតំបន់សម្បទាននេះ សំបូរប្រភពទឹកស្រទាប់លើ មធ្យម នៅក្នុងទីតាំងសម្បទានរបស់ក្រុមហ៊ុន យើងសង្កេតឃើញមានប្រព័ន្ធអូរជាច្រើន តែប្រព័ន្ធផ្លូវទឹកទាំងនេះភាគច្រើនរីងគោកនៅរដូវប្រាំងពោលគឺមានតែ **អូរធំ និង អូរព្រៀល** ដែលហូរកាត់ចំណុចកណ្តាលទីតាំង ដីសម្បទានរបស់ក្រុមហ៊ុន ដែលអូរទាំងនេះមានទឹកដក់គ្រប់រដូវ (ហូរចាក់ចូលទៅអូរ) ជាប្រចាំ និងជាប្រភពទឹកប្រើប្រាស់ដ៏សំខាន់របស់ប្រជាជននៅតំបន់នោះទាំងមូល ហើយក៏ជាជំរកត្រីផងដែរ។ តាមការសាកសួរពីប្រជាជនមូលដ្ឋាន បញ្ជាក់ថា ពួកគាត់ធ្លាប់នេសាទបាននូវ ប្រភេទត្រីមួយចំនួន (ទាំងប្រភេទត្រីស និងត្រីខ្មៅ) នៅក្នុងតំបន់នោះគឺ ត្រីឆ្ពិន ត្រីរ៉ស់ ត្រីក្រហែរ ត្រីអាចម៍កុក ត្រីស្រកាក្តាម ត្រីក្រោស...។

**២៤១.** ប្រភពចំណូលសំខាន់របស់ពួកគាត់ គឺអាស្រ័យលើមុខរបរធ្វើស្រែ (ទិន្នផលស្រូវ១-២តោនក្នុង១ហិកតា ១គីឡូក្រាមស្រូវលក់បានតំលៃ ១០០០ រៀល) និងចំការ (ចំងាយ៥ គ.ម ពីផ្ទះ)។ ចំណែកមុខរបរ

បន្ទាប់បន្សំផ្សេងទៀតគឺ ការចិញ្ចឹមសត្វជាលក្ខណៈ គ្រួសារ ស៊ីឈ្នួលដកស្ទូង ដាំដំឡូងមី ដំឡូងជ្វា សណ្តែក ត្រសក់ ស្វាយចន្ទី អំពៅ ចេក ពោត និងការ ចូលព្រៃ ដើម្បីទាញផលពីអនុផលព្រៃឈើដូចជា កាប់កូនឈើ របងផ្ទះ កាប់ឈើធ្វើជន្ទល់ធ្វើសំណង់ផ្ទះថ្ម ឬព្រះវិហារ ឈើគ្រាក់ ដងជ័រ បោចវល្លិ៍ វាយផ្តៅ សឹង បេះផ្លែឈើ (ផ្លែគុយ) រកទំពាំង ដកផ្សិត ជីកដំឡូងទៀន កាប់អុស (តែកម្រមានឈ្មួញចូលមកទិញណាស់) ដុតធ្យូង និងធ្វើអាជីវកម្មអារឈើ ខ្នាតតូចជាដើម។ ការចិញ្ចឹមគោ ក្របីបន្តិចបន្តួចរបស់ពួកគាត់ គឺសំរាប់ប្រើប្រាស់ជាមធ្យោបាយធ្វើស្រែ ចំការ ផង និងដឹកឈើផង។ ចំណែកឯ មាន់ និងជ្រូកវិញគេចិញ្ចឹមជាលក្ខណៈប្រពៃណី មានឈ្មួញមកទិញដល់ ភូមិតែម្តង ដោយមាន់១គ.ក្រថ្លៃ ១៥០០០-១៨០០០រៀល ប៉ុន្តែគ្រួសារភាគច្រើនគ្មានមាន់លក់ទេ។ ការចិញ្ចឹមជ្រូកវិញ ក៏មិនសូវជាចិញ្ចឹម ច្រើន ដោយសារកូនជ្រូកថ្លៃ ហើយចំណីក៏ថ្លៃទៀត គ្រួសារខ្លះចិញ្ចឹម១-២ក្បាល ឯខ្លះ ទៀតមិនមានចិញ្ចឹម ទេ។ ពួកគាត់ចិញ្ចឹមជ្រូកមិនមែនជាលក្ខណៈអាជីវកម្មទេ គឺគ្រាន់សំរាប់ដោះស្រាយពេលរវល់បុណ្យទាន ឬការកូនចៅតែប៉ុណ្ណោះ។ ក្រៅពីមុខរបរធ្វើស្រែចំការ មានបងប្អូនខ្លះមានមុខរបរលក់ ចាប់ហួយសំរាប់ផ្គត់ផ្គង់ ជីវភាពបន្ថែម ប៉ុន្តែការលក់ដូររបស់គាត់មិនសូវជាកាក់កបប៉ុន្មានទេ ខ្លះអស់ដើម ដោយសារគេជំពាក់ច្រើន ពេក វាមិនដូចនៅទីផ្សារឡើយ។

**២៤២.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៏មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយៗ។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រនៅក្នុងខេត្តកំពង់ធំមានៈ ២៩.១០ភាគរយ (១៥៨,៩០ពាន់) លើចំនួនប្រជាជនសរុប ៦២៤.៨៤៦នាក់ ក្នុងនោះមាន ៦២១.៨៣៣នាក់ ឬស្មើនឹង ៩៩ភាគរយ រស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀងអង្គការសហប្រជាជាតិឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៏ឆ្នាំ២០០៤)។

**២៤៣.** លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៏ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល) នៅក្នុងសហគមន៏ដាច់ស្រយាលទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀប ធៀបជាមួយនឹងគ្រួសារសហគមន៏នៅក្នុងតំបន់ដទៃទៀតរបស់ប្រទេសកម្ពុជា។ ការសិក្សាបានបង្ហាញឱ្យ ឃើញថា អ្នកភូមិដែលរស់នៅតាមដងផ្លូវក៏ដូចជាប្រជាជនដែលរស់នៅតាមភូមិក្រយា ភូមិដងក្តារ ភូមិតាម៉ិញ ភូមិសុភមង្គល ភូមិត្រពាំងព្រីង និងភូមិទក់ ភូមិអូរទឹកថ្លា ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំដែរ ពុំបានទទួល ការផ្គត់ផ្គង់ អគ្គិសនីជាមូលដ្ឋានទេ។ មានប្រជាជនចំនួនតិចតួចគ្រួសារណាស់ដែលមានម៉ាស៊ីនភ្លើងខ្លួនឯងប្រើក្នុង ពេលដែលគ្រួសារភាគច្រើនទៀតមានលទ្ធភាពប្រើប្រាស់អាគុយ និងចង្កៀងប្រេងកាតសំរាប់បំភ្លឺនៅពេលយប់។ រីឯប្រភពថាមពលសំខាន់សំរាប់ការចំអិនអាហាររបស់ពួកគាត់គឺអុស និងធ្យូង។



Draft

២៤៤. ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើនគឺប្រើប្រាស់ផ្លូវជាតិលេខ៦ ដែលជាផ្លូវយ៉ាងសំខាន់នៅក្នុងតំបន់នេះ។ ផ្លូវជាតិលេខ៦បានចាប់ផ្តើមពីភ្នំពេញ ដោយឆ្លងកាត់ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ហើយចប់នៅកាន់មាត់ច្រកអន្តរជាតិប៉ោយប៉ែត ក្នុងស្រុកអូរជ្រៅ។ រីឯផ្លូវដែលតភ្ជាប់ផ្លូវជាតិទៅកាន់ទីប្រជុំជនឃុំក្រយាជាផ្លូវដីមានក្រាលគ្រួសក្រហមដោយអន្លើ (ពីទីប្រជុំជនកំពង់ថ្មទៅម្តុំទំនប់ទឹក១មករា) បន្ទាប់មកគឺជាផ្លូវក្រាលគ្រួសក្រហម ហើយនៅត្រង់កំណាត់ផ្លូវនេះ ផ្លូវមានសភាពទ្រុឌទ្រោមនិងខូចខាតដោយកន្លែង។ ចំណែកឯការធ្វើដំណើរពីទីប្រជុំជនឃុំក្រយាទៅកាន់ភូមិដទៃទៀតក៏មានការលំបាកខ្លាំងដែរ។ ដោយសារតែការធ្វើដំណើរចេញចូលមានលក្ខណៈអន់ថយ ដូច្នេះហើយទើបធ្វើអោយការប្រាស្រ័យទាក់ទងរវាងសហគមន៍ទាំងនេះជាមួយនឹងតំបន់ខាងក្រៅ ពុំមានលក្ខណៈទូលំទូលាយ និងទទួលបានការយកចិត្តទុកដាក់តិចតួចពីបណ្តាភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ ដែលក្នុងនោះមានការផ្គត់ផ្គង់ទឹកស្អាត ថាមពល សាលារៀន និងមណ្ឌលសុខភាពជាដើម។

Draft

## ៩. អនុសាសន៍

យោងលើសេចក្តីសន្និដ្ឋានស្តីពីហេតុប៉ះពាល់បរិស្ថាននិងសង្គម ក្រុមការងារសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម:

**២៤៥.** នៅក្នុងដំណើរប្រតិបត្តិការគំរោងសាម៉ីវិនិយោគិន ត្រូវតែអនុវត្តផែនការគ្រប់គ្រងបរិស្ថានទៅតាមវិធានការណ៍នានាដូចមានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន ដូចបានពណ៌នានៅក្នុងតារាង ៦-១ និងតារាង ៦-៣ នោះស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធ ត្រូវតាមដានពិនិត្យនិងវាយតំលៃទៅលើសកម្មភាពនៃការអភិវឌ្ឍន៍របស់វិនិយោគិន ជាប្រចាំទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

**២៤៦.** ចំពោះការបង្កើតរោងចក្រកែច្នៃផលិតផលកៅស៊ូ ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍ IESIA មួយដាច់ដោយឡែក ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ និង ដើម្បីឱ្យស្របទៅតាមអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

Draft

ភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

**នាយក ក្រុមហ៊ុន**

TAN BIEN KAMPONGTHOM APPIVATH CAOUTCHOUC Co., Ltd.

TRAN VANTOAN

ភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១

**នាយក**

Green Consultancy Firm

KINGDOM OF CAMBODIA

បណ្ឌិត. លី_សុពណ៌_មុន្នី

## ឯកសារយោង


1. A Poverty Profile of Cambodia, MoP, 1997
2. Asia-Pacific Tropical Forestry: Ecological Disaster or Sustainable Growth, RAPA, Bangkok, 1994
3. Asian Development Bank. 1997. Involuntary Resettlement. *Operations Manual*. Manila. *Environment Division, Office of Environment and Social Development*. Manila.
4. ———. 2003. *Environmental Assessment Guidelines*. Manila.
5. Agricultural Strategies and Policy Framework for Sustainable Food Security and Poverty Alleviation, Cambodia, May 2000
6. Biodiversity the Life of Cambodia. Edited by Jady Smith, 2001
7. Cambodia Poverty Assessment, MoP, 1999
8. Cambodia Forestry Code of Practice for Harvesting dated 26 July 1999
9. Conflict and Natural Resource Management, FAO, 2000
10. FAO Model Code of Forest Harvesting Practice, Rome 1995
11. FAO Model Code of Forest Harvesting Practice, Rome 1996
12. Forest Concession Management Planning Manual, dated March 2001
13. Forest Inventory in Eastern Mekong by B. Rollet 1962
14. Forest Resources Assessment 1990, in Tropical Countries, FAO, Rome, 1993
15. General Population Census of Cambodia – Final Census Result of 1998
16. Gene-Ecological Zonation of Cambodia – Forestry Administration, DANIDA, German Development Services, December, 2003
17. Guidelines For Preliminary EIA for Forest Harvesting – 27 January 1995
18. Handbook of the Policy and Basic Procedure of EIA in Sarawak – 27 January 1995
19. Landuse Capability Map 1997/97
20. National Environmental Planning Manual 1998-2002
21. National Forest Policy of Cambodia, WB, UNDP, FAO, April 1996
22. National Weather Report From Ministry of Water Resource and Meteorology
23. Non-wood Forest Products for Rural Income and Sustainable Forestry, FAO, Rome, 1995
24. Royal Decree on the declaration of Protected Areas dated 1st November 1993
25. Satellite Imageries map interpreted by DFW year 1996/97/2000
26. Strategic Environmental Framework for the Greater Mekong Sub-region: Integrating Development and Environment in the Transport and Water Resource Sectors, Stockholm Environment Institute
27. Soil Survey Report of Charles D. Crocker 1962/63
28. The Atlas of Cambodia, National Poverty and Environmental Maps, DANIDA, 2006
29. Vegetation of Cambodia 1972 & 1996/97 and 2000.
30. DANIDA., 2003. Gene-Ecological Zonation of Cambodia. Cambodian Tree Seed Project Institute Capacity Building of the Tree Seed Sector. Forestry Administration. pp 19-25.


Draft